**សកម្មភាព៖ លាយពណ៌ធ្វើជាសត្វ**មេអំបៅ

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ   (ការស្វែងយល់ដោយសង្កេត)

បំណិនពិចារណា (ការយល់ដឹងអំពីហេតុ និងផល)

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**បុរេគណិត**

**ទំហំ និងពណ៌** (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

**(វិទ្យាសាស្ត្រ)** ប្រាប់បានពីរបៀបនៃការពិសោធន៍។

លក្ខណៈ ស្ថានភាពវត្ថុអ្វីមួយ។

**(សិក្សាសង្គម)** ផាត់ពណ៌ដើម្បីបង្កើតជារូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលគេបានបង្កើត។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង   “តើនរណាជាអ្នកលាបពណ៌មេឃ?”   ។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖  ទឹកពណ៌ក្រហម លឿង ខៀវ និងក្រដាសស ។

**ការរៀបចំ** ៖ អនុវត្តបង្កើតជាសត្វមេអំបៅ និងរៀបចំដើម្បីបង្ហាញសកម្មភាពនេះទៅកាន់ក្មេងទាំងអស់។

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង**លាយពណ៌ធ្វើជាសត្វ**មេអំបៅ ជាមួយកូនៗទាំងអស់គ្នា។

2. បង្ហាញក្មេងៗអំពីទឹកពណ៌សម្រាប់បង្កើតជាសត្វមេអំបៅ។
3. ហើយសរសេរពណ៌នៅលើក្តារខៀនទាំងអស់ក្រោយពេលបង្ហាញរួច។
4. សួរក្មេងៗថា៖ តើពណ៌មួយណាដែលកូនៗចូលចិត្ត?
5. ពន្យល់ថាពណ៌ក្រហម ពណ៌លឿង និងពណ៌ខៀវ គឺជាពណ៌ដើមគេ។
6. គ្មានពណ៌ណាផ្សេងទៀតដែលអាចលាយចេញជាពណ៌ក្រហម លឿង និងពណ៌ខៀវនោះទេ។
7. ប្រាប់ក្មេងៗ៖ តែពណ៌ទាំង ៣នេះអាចបង្កើតទៅជាពណ៌ផ្សេងៗបានទាំងអស់។
8. សួរក្មេងៗថា៖ តើកូនៗគិតយ៉ាងណានៅពេល ដែលលាយពណ៌ក្រហម និងលឿងចូលគ្នា?
   តើកូនៗគិតយ៉ាងណានៅពេល ដែលលាយពណ៌ខៀវ និងលឿងចូលគ្នា?
   តើកូនៗគិតយ៉ាងណានៅពេល ដែលលាយពណ៌ខៀវ និងក្រហមចូលគ្នា?
9. ចំណែកឯពណ៌ទឹកក្រូច បៃតង និងពណ៌ស្វាយគឺជាពណ៌មេបន្ទាប់ពណ៌ទាំង ៣ខាងលើ។
10. ចែកក្រដាសធម្មតា និងបង្ហាញក្មេងៗពីរបៀបបត់ក្រដាសជាពីរស្មើគ្នា ។
11. បង្ហាញពួកគេពីរបៀបធ្វើសកម្មភាពនេះឱ្យក្មេងៗមើលផ្ទាល់៖

- បត់ក្រដាសជាពីរស្មើគ្នា ។
- លាតក្រដាស រួចពង្រាយទឹកពណ៌ដែលមានផ្សេងៗពីគ្នាដូចជាដំណក់ទឹកភ្លៀង នៅផ្នែកទាំង២នៃក្រដាសនោះ (វាគួតែពង្រាយទឹកពណ៌គ្រប់គ្រាន់ដើម្បីបង្កើតជាមេអំបៅ)... តែកុំពង្រាយទឹកពណ៌ច្រើនពេក កុំឱ្យពេលយើងបត់ក្រដាសម្តងទៀត វាហូរទឹកពណ៌ចេញមកក្រៅ។
- បត់ក្រដាសជាពីរស្មើគ្នាម្តងទៀត និងសង្កត់ពីលើក្រដាសនោះ ដើម្បីឱ្យទឹកពណ៌ជាប់ពេញក្រដាស។
- បើកក្រដាសម្តងទៀត ដើម្បីបានឃើញគំរូ និងពណ៌ដែលអ្នកបានបង្កើតនោះ។
- ទុកឱ្យវាស្ងួតសិន។
- បត់វាម្តងទៀត និងកាត់ក្រដាសជារាងសត្វមរអំបៅ។

12. ចែកចាយទឹកពណ៌។
13. ជួយក្មេងៗប្រសិនបើអាចទៅរួច។
14. ចែកក្រដាសធម្មតាឱ្យទៅក្មេងៗមួយទៀត ដូច្នេះពួកគេអាចលាយពណ៌ផ្សេងៗទៀត។
15. ខណៈពេលដែលពួកគេកំពុងរងចាំឱ្យក្រដាសរបស់ពួកគេស្ងួតនោះ។
    ចូរនិយាយអំពីពណ៌ដែលពួកគេបានបង្កើត និងនិយាយម្តងទៀតថា ពណ៌ក្រហម ពណ៌លឿង និងពណ៌ខៀវគឺជាពណ៌ដើមពីព្រោះថាគ្មានពណ៌ណាដែលអាចបង្កើតបានជាពណ៌ទាំងបីនេះទេ។

16. ហើយពណ៌បៃតង ពណ៌ទឹកក្រូច និងពណ៌ស្វាយ គឺជាពណ៌បន្ទាប់ពីពណ៌ទាំង៣ខាងលើពីព្រោះ ពណ៌ទាំងនេះបានបង្កើតដោយលាយពណ៌ដើម ២ពណ៌ចូលគ្នា។
17. នៅពេលដែលទឹកពណ៌ស្ងួតហើយនោះក្មេងៗអាចកាត់ ឬហែកវាជារាងមេអំបៅបានជាការស្រេច។







